ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

នាយកដ្ឋានបុគ្គលិក

លេខ ១២៥១

# ញត្តិគាំទ្រ

## សាលដីកាស្ថាពររបស់តុលាការកំពូលរំលាយគណបក្សសង្គ្រោះជាតិ

## នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំនាយកដ្ឋានបុគ្គលិក ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ បន្ទាប់ពីបានតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះព្រឹត្តិការណ៍ដ៏មានសារសំខាន់ជាអាយុ ជីវិតរបស់ប្រទេសជាតិពាក់ព័ន្ធនឹងសវនាកាត់ទោស " **រំលាយគណបក្សសង្គ្រោះជាតិ** " របស់តុលាការកំពូល នាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងភ្នំពេញ យើងខ្ញុំសូមសម្តែងការគាំទ្រយ៉ាងពេញទំហឹងចំពោះសាលដីកាស្ថាពរដែលបានសម្រេច " **រំលាយគណបក្សសង្គ្រោះជាតិ** " ដែលជាទង្វើក្បត់ជាតិរបស់គណបក្សសង្គ្រោះជាតិ និងក្បត់ឆន្ទប្រជាជននាពេលកន្លងមក ។

យើងខ្ញុំទាំងអស់គ្នា បានត្រៀមលក្ខណៈរួចជាស្រេចទប់ទល់រាល់ឧបាយកលរបស់គណបក្សប្រឆាំងដែលឃុបឃិតជាមួយបរទេស ក្នុងគោលបំណងបំផ្លាញសន្តិភាព និងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ និងប្តេជ្ញាដាច់ខាតការពារសន្តិភាពនិងរាជរដ្ឋាភិបាល ស្របច្បាប់ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា** ។

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំនាយកដ្ឋានបុគ្គលិក ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងរាល់វិធានការណ៍តាមផ្លូវច្បាប់ និងសាលដីកាស្ថាពររបស់តុលាការកំពូល និងប្រកាសម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនិងការពារនីតិរដ្ឋក្នុងបំណងរួមចំណែកថែរក្សាសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សង្គមនិងសណ្តាប់ធ្នាប់សាធារណៈ និងដើម្បីភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៧

**នាយក**

នាយឧត្តមសេនីយ៍.**មាស_សំអុល**